ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈរដ្ឋមន្ត្រី
រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ
លេខ: ៦៧៤ មស

# សេចក្តីសម្រេច
# ស្តីពី
# ការចាត់តាំងនាយកគ្រប់គ្រងកម្មវិធីកន្សោមអទិភាព
# និងការបង្កើតក្រុមការងារកន្សោមអាទិភាព
# ប្រចាំរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ

## រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ

- បានឃើញរដ្ឋធម្មនុញ្ញនៃរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសឱ្យប្រើច្បាប់ធម្មនុញ្ញបន្ថែមសំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ
- បានឃើញ ព្រះរាជក្រឹត្យលេខ សន/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់រៀបចំ និងការប្រព្រឹត្តទៅទីស្តីការគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២៤ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ពីការបង្កើតរដ្ឋាភិបាលមុខងារសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ១៩ អនក្រ.បក ចុះ ថ្ងៃទី ២៨ ខែ ឧសភា ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ៨៣ អនក្រ.បក ចុះថ្ងៃទី ១៣ ខែ សីហា ឆ្នាំ ២០០២ ស្តីពីការបង្កើត និងដាក់ឱ្យដំណើរការកម្មវិធីកន្សោមអាទិភាព
- យោងតាមសំណូមពរចាំបាច់

# សម្រេច

**ប្រការ ១**: ចាត់តាំងឯកឧត្តម **រស់ សុផាន់** អនុរដ្ឋលេខាធិការ ជានាយកគ្រប់គ្រងកម្មវិធីកន្សោមអាទិភាពប្រចាំរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ ។

**ប្រការ ២**: បង្កើតក្រុមការងារកន្សោមអាទិភាព ដែលមានសមាសភាពដូចខាងក្រោម ៖

| | | | |
|---|---|---|---|
| ១. ឯកឧត្តម | **ហ៊ុយ ចាន់នី** | អគ្គាធិការ | ជាប្រធាន |
| ២. ឯកឧត្តម | **ថៅ សេដ្ឋាណា** | អគ្គនាយក | អនុប្រធាន |
| ៣. លោក | **ជុំគ មុន្នី** | អគ្គាធិការរង | អនុប្រធាន |
| ៤. លោក | **ជួប សុផាន** | ប្រធាននាយកដ្ឋាននីតិកម្ម និងវិវាទមុខងារសាធារណៈ | សមាជិក |
| ៥. លោក | **ឆិន សុខឃួន** | ប្រធាន នាយកដ្ឋានត្រួតពិនិត្យរដ្ឋបាល និងគ្រប់គ្រងមន្ត្រីរាជការស៊ីវិល | សមាជិក |
| ៦. លោក | **ខៀវ ច័ន្ទប៊ុនធឿន** | ប្រធាននាយកដ្ឋានក្របខណ្ឌសិក្សាស្រាវជ្រាវបណ្តុះបណ្តាល | សមាជិក |
| ៧. លោក | **កែវ ឡុង** | ប្រធាននាយកដ្ឋានរដ្ឋបាល និងហិរញ្ញកិច្ច | សមាជិក |
| ៨. លោក | **ស៊ីន សុឃុន** | ប្រធានមជ្ឈមណ្ឌលធនធានអាស៊ានកម្ពុជា | សមាជិក |

**ប្រការ ៣**: ក្រុមការងារកន្សោមអាទិភាពនេះមានភារកិច្ច ៖

- ជួយនាយកគ្រប់គ្រងកម្មវិធីកន្សោមអាទិភាពនូវការងារកន្សោមអាទិភាព នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ ។
- ធ្វើទំនាក់ទំនងការងារជាមួយក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល និងគណៈកម្មាធិការរៀបចំគម្រោងកន្សោមអាទិភាពរបស់ក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល ។
- កំណត់អត្តសញ្ញាណបេសកកម្មអាទិភាព កំណត់អាទិភាពនៃបេសកកម្មអាទិភាព រៀបចំសំណើសុំដាក់ឱ្យដំណើរការកន្សោមអាទិភាព វាយតម្លៃពាក្យសុំជ្រើសរើសចូលជាសមាជិកកន្សោមអាទិភាព និង បំពេញភារកិច្ចផ្សេងៗទៀតតាមចាំបាច់ ។
- រៀបចំលិខិតបទដ្ឋាននានាតាមដំណាក់កាលនីមួយៗ ដែលពាក់ព័ន្ធនឹងការងារកន្សោមអាទិភាព ។

**ប្រការ ៤**: សមាជិកក្រុមការងារកន្សោមអាទិភាពត្រូវចូលរួមប្រជុំតាមការអញ្ជើញ និងក្រោមការដឹកនាំរបស់នាយកគ្រប់គ្រងកន្សោមអាទិភាព ឬក្រោមការដឹកនាំរបស់ប្រធានក្រុមការងារតាមការប្រគល់ភារកិច្ចនាយក ។

**ប្រការ ៥**: សេចក្តីសម្រេចទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីនេះ ចាត់ទុកជានិរាករណ៍ ។

**ប្រការ ៦**: អគ្គនាយកនៃអគ្គនាយកដ្ឋាន អគ្គាធិការនៃអគ្គាធិការដ្ឋាន នាយកខុទ្ទកាល័យ ប្រធាននាយកដ្ឋានរដ្ឋបាល និងហិរញ្ញកិច្ច ឯកឧត្តម អស់លោក ដូចមានឈ្មោះក្នុងប្រការ ១ និងប្រការ ២ ខាងលើ មានភារកិច្ចអនុវត្តសេចក្តីសម្រេចនេះឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី ១៩ ខែ សីហា ឆ្នាំ ២០០៤

**ហត្ថលេខា និងត្រា**

**ពេជ្រ ប៊ុនធិន**

***<u>កន្លែងទទួល:</u>***

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល

  "ដើម្បីជូនជ្រាប"
- ដូចប្រការ ៦
- ឯកសារ-កាលប្បវត្តិ